# ចប់

# បញ្ជីអត្ថបទ

***


**មេរៀនទី ១ ភាពពិតនៃព្រះគម្ពីរ** ..................................................... ៣

I. ព្រះគម្ពីរវិសុទ្ធជាអ្វី? ..................................................... ៣

II. ព្រះគម្ពីរមានសារៈសំខាន់យ៉ាងណា? ..................................... ៣

**ក.** ចំពោះមនុស្សជាតិ ..................................................... ៣

**ខ.** ចំពោះគ្រីស្តបរិស័ទ ..................................................... ៤

**គ.** ចំពោះមនុស្សទូទៅ ..................................................... ៤

III. ហេតុអ្វីវានជាគេសរសេរព្រះគម្ពីរ? ..................................... ៤

IV. កណ្ឌនៃព្រះគម្ពីរ ..................................................... ៥

V. ព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ..................................................... ៥

VI. ព្រះគម្ពីរសម្ពន្ធមេត្រីថ្មី ..................................................... ៨

**មេរៀនទី ២ ហេតុអ្វីយើងអានព្រះគម្ពីរ** ..................................................... ៩

១. ដើម្បីដឹងថាព្រះជាម្ចាស់ចង់ឲ្យយើងធ្វើអ្វី ..................................... ៩

២. ដើម្បីទុកជាអាហារបំប៉នរបស់យើង ..................................... ៩

៣. ដើម្បីឲ្យយើងចេះវែកញែក ..................................... ៩

៤. ដើម្បីឲ្យយើងសុចរិត ..................................... ១០

៥. ដើម្បីឲ្យយើងមានថាមពលយកឈ្នះបាន ..................................... ១០

៦. ដើម្បីអ្នកបានទទួលព្រះបន្ទូល ..................................... ១១

**មេរៀនទី ៣ របៀបអានព្រះគម្ពីរវិធីអានព្រះគម្ពីរ** ..................................... ១២

**ក.** វិធីទី -១ ..................................................... ១៣

**ខ.** វិធីទី -២ ..................................................... ១៧

**មេរៀនទី ៤ ហេតុផល ៨ យ៉ាងដែលគ្រីស្តបរិស័ទចូលរួមថ្វាយអភិបូជាប្រចាំថ្ងៃ** .១៩

**មេរៀនទី ៥: ការចូលរួមថ្វាយអភិបូជាថ្ងៃអាទិត្យ** ..................................... ២១




## ខ. ការថ្វាយបង្គំព្រះជាម្ចាស់ជាឯកជនមិនគ្រប់គ្រាន់ទេ

ចាប់តាំងពីកកើតព្រះសហគមន៍មក គ្រីស្តបរិស័ទដឹងយ៉ាងច្បាស់ថា ការរស់នៅជាគ្រីស្តបរិស័ទ មិនមែនជារឿងឯកជនទេ គឺជាការត្រាស់ហៅឲ្យរស់នៅរួមជាមួយគ្នា ។ ពេញមួយសប្តាហ៍ ខណៈពេលដែលអ្នកថ្វាយបង្គំព្រះជាម្ចាស់ជាឯកជន នោះអ្នកក៏ត្រូវយកចិត្តទុកដាក់ថ្វាយបង្គំព្រះអង្គរួមជាមួយបងប្អូនក្នុងព្រះសហគមន៍ដែរ ដ្បិតទម្រង់ដ៏សំខាន់នៃការថ្វាយបង្គំ ព្រះជាម្ចាស់ គឺសាធារណៈ និងសហគមន៍ ដែលនេះជាហេតុធ្វើឲ្យអភិបូជានៅថ្ងៃអាទិត្យមានសារៈសំខាន់យ៉ាងខ្លាំង ។

## គ. តើអ្នកត្រូវបានលើកលែងចូលរួមថ្វាយអភិបូជាថ្ងៃអាទិត្យទេ?

តាមការណែនាំរបស់ព្រះសហគមន៍ ការចូលរួមថ្វាយអភិបូជា គឺជាសំណូមពរដ៏ចាំបាច់ ដើម្បីអ្នកបានទទួលការលើកលែងទោសឲ្យរួចពីបាបដែលបណ្តាលឲ្យស្លាប់ ។ ចូលរួមថ្វាយអភិបូជាជាសំណូមពរមួយ ក្នុងចំណោមសំណូមពរផ្សេងទៀត ប៉ុន្តែមានករណីខ្លះអ្នកត្រូវបានលើកលែង៖

ប្រសិនបើអ្នកឈឺ អ្នកខ្សោយកម្លាំង ឬប្រសិនបើមានអាកាសធាតុអាក្រក់ខ្លាំងបណ្តាលឲ្យការធ្វើដំណើររបស់អ្នកមិនមានសុវត្ថិភាព នោះអ្នកអាចត្រូវបានលើកលែងពីការចូលរួមថ្វាយអភិបូជា ។ ក្នុងករណីខ្លះ លោកអភិបាលលោកបូជាចារ្យអាចលុបកម្មវិធីថ្វាយអភិបូជាបាន ដើម្បីការពារសុវត្ថិភាពគ្រីស្តបរិស័ទ ។ អ្នកគួរតែមានហេតុផលត្រឹមត្រូវ ក្នុងការខកខានចូលរួមថ្វាយអភិបូជា ។

ព្រះសហគមន៍តម្រូវឲ្យអ្នកស្ថិតនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ពេលអ្នកចូលរួមអភិបូជាបន្ទាប់ និងចូលរួមក្នុងពិធីអរព្រះគុណព្រះជាម្ចាស់ ។ ប្រសិនបើហេតុផលរបស់អ្នក មិនអាចទទួលយកបានដោយព្រះសហគមន៍ទេ នោះអ្នកត្រូវមានការអនុញ្ញាតពីលោកបូជាចារ្យរបស់អ្នក ។

## មេរៀនទី ៥ ការចូលរួមថ្វាយអភិបូជាថ្ងៃអាទិត្យ

ព្រះសហគមន៍កាតូលិក ណែនាំគ្រីស្តបរិស័ទឲ្យចូលរួមថ្វាយអភិបូជារាល់ថ្ងៃអាទិត្យទុកជាកាតព្វកិច្ច ។ អភិបូជាគឺជាការប្រារព្ធពិធីអរព្រះគុណព្រះជាម្ចាស់ និងពិធីប្រសិទ្ធិពរលើនំប៉័ង និងស្រាឲ្យទៅជាព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត ។

មនុស្សជាច្រើនមិនយល់ពីមូលហេតុ ដែលព្រះសហគមន៍ប្រារព្ធអភិបូជារាល់ថ្ងៃអាទិត្យនេះទេ ។ ចម្លើយបានរកឃើញនៅក្នុងក្រឹត្យវិន័យដប់ប្រការ ដែលព្រះជាម្ចាស់បានប្រគល់ដល់លោកម៉ូសេកាលពីរាប់ពាន់ឆ្នាំមុន ។

### ក. កាតព្វកិច្ចនៃថ្ងៃអាទិត្យ

វិន័យដប់ប្រការ ត្រូវបានអ្នកជឿចាត់ទុកថាជាច្បាប់ ជាក្រមសីលធម៌ និងជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានប្រទានមក ។ វិន័យទី ៣ មានចែងថា "ត្រូវចងចាំថ្ងៃសប្ប័ទ ហើយត្រូវសម្រាកនៅថ្ងៃនោះ" ។ តាមវិន័យនេះ ជនជាតិយូដាគេសម្រាកនៅថ្ងៃសៅរ៍ ។ ចំពោះគ្រីស្តបរិស័ទបានប្តូរពីថ្ងៃសៅរ៍ទៅថ្ងៃអាទិត្យវិញ ដ្បិតជាថ្ងៃដែលព្រះយេស៊ូមានព្រះរស់ឡើងវិញ ពីសេចក្តីស្លាប់ ។ ព្រះសហគមន៍ទូន្មានថា គ្រីស្តបរិស័ទមានកាតព្វកិច្ចបំពេញតាមវិន័យទី៣នេះ ដោយឈប់សម្រាកពីការងាររបស់ខ្លួននៅថ្ងៃអាទិត្យ មកចូលរួមថ្វាយអភិបូជា ដ្បិតការថ្វាយបង្គំព្រះជាម្ចាស់ គឺជាការសំខាន់បំផុតរបស់គ្រីស្តបរិស័ទ ។

សេចក្តីអប់រំជំនឿរបស់ព្រះសហគមន៍កាតូលិកមានចែងថា "អ្នកត្រូវចូលរួមថ្វាយអភិបូជានៅរាល់ថ្ងៃអាទិត្យ និងថ្ងៃបុណ្យដ៏វិសុទ្ធចាំបាច់ផ្សេងទៀត និងអ្នកត្រូវសម្រាកពីការងារពលកម្ម" ។ រាល់ថ្ងៃអាទិត្យ គឺជាថ្ងៃកាតព្វកិច្ច ជាថ្ងៃដ៏វិសុទ្ធចាំបាច់ត្រូវបំពេញ ដើម្បីឲ្យអ្នកលូតលាស់នៅក្នុងជំនឿ ។ អ្នកត្រូវតែបំពេញកាតព្វកិច្ចនេះ តាមដែលអ្នកអាចធ្វើបាន ។



## មេរៀនទី ១ ភាពពិតនៃព្រះគម្ពីរ

### I. ព្រះគម្ពីរវិសុទ្ធជាអ្វី?

ព្រះគម្ពីរ គឺជាសំណេរដ៏សក្ការៈរៀបរាប់ អំពីទំនាក់ទំនងរបស់ព្រះជាម្ចាស់ចំពោះមនុស្សលោក និងមានចែងពីប្រភព និងពីកំណត់ត្រានៃការទាក់ទងរបស់ព្រះអង្គ ជាមួយពិភពលោកដែលព្រះអង្គបង្កើត ។ ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលសរសេរជាភាសារបស់មនុស្ស យោងតាមឆន្ទៈរបស់ព្រះអង្គ ។ ព្រះគម្ពីរក៏រៀបរាប់ពីប្រវត្តិនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដែរ ហើយក៏ជាសញ្ញានៃវត្តមានរបស់ព្រះអង្គគង់នៅជាមួយពួកគេ ។

ព្រះគម្ពីរ ត្រូវនឹងភាសាអង់គ្លេសថា (bible) មកពីភាសាក្រិកថា (tabilia) មានន័យថា "សៀវភៅ" ។ ព្រះគម្ពីរគឺជាបណ្ណាល័យ ឬជាការប្រមូលសៀវភៅច្រើនក្បាលរបស់អ្នកនិពន្ធច្រើនគ្នាមកតែមួយក្បាល ។ ព្រះគម្ពីរដូចដែលយើងមានសព្វថ្ងៃ ត្រូវបានគេសរសេរក្នុងរយៈពេលជាងមួយពាន់ឆ្នាំ ។ គេសរសេរជាភាសាផ្សេងៗ (ហេប្រឺ, អារ៉ាម, ក្រិក) និងនៅកន្លែងក៏ផ្សេងគ្នាដែរ (ក្រិក, មេសូប៉ូតាមី, អេហ្ស៊ីប, បាប៊ីឡូន, ប៉ាឡេស្ទីន) តាមរយៈមនុស្សដែលព្រះជាម្ចាស់បានបំផុសគំនិត ។

### II. ព្រះគម្ពីរមានសារៈសំខាន់យ៉ាងណា?

**ក) ចំពោះមនុស្សជាតិ៖**

១. ជាកំណប់នៃប្រាជ្ញា សម្រាប់បំភ្លឺគំនិតមនុស្សនិងបានដឹកនាំមនុស្សជំនាន់មុនយើង ។

២. ឲ្យមនុស្សមានការយល់ដឹងយ៉ាងជ្រាលជ្រៅអំពីអត្ថន័យនៃជីវិត ។

៣. មានឥទ្ធិពលយ៉ាងជ្រាលជ្រៅលើគំនិតសាសនានាសម័យបច្ចុប្បន្ន ។

៤. បង្ហាញអំពីជំនឿ និងពីប្រវត្តិនៃសហគមន៍សាសន៍យូដានិងគ្រីស្តបរិស័ទ ។

៥. គម្ពីរបន្តជះឥទ្ធិពលលើពិភពលោកសព្វថ្ងៃ ហើយកំពុងតែបន្តដឹកនាំសង្គមមនុស្សកាន់ច្រើនទៅៗ

**ខ) ចំពោះគ្រីស្តបរិស័ទ**

១. ព្រះគម្ពីរជាសៀវភៅដ៏សក្ការៈ និងជាប្រភពនៃជំនឿសាសនា ។

២. ជាសេចក្តីពិតដែលព្រះជាម្ចាស់បើកបង្ហាញ ពីការសង្គ្រោះរបស់ព្រះអង្គចំពោះមនុស្សលោក (អស ៤០) ។

៣. ជាសំណុំច្បាប់សម្រាប់ការរស់នៅឲ្យស្របតាមព្រះហឫទ័យនៃព្រះជាម្ចាស់ និងជាចង្កៀងបំភ្លឺដំណើរជីវិត (សភ ១១៩, ១០៥) ។

៤. ជាគ្រឹះនៃការថ្វាយបង្គំព្រះជាម្ចាស់ ដែលផ្តល់ជីវិត និងមានមហិឫទ្ធិ (ហប ៤,១២) ។

៥. ជាឯកសារប្រវត្តិសាស្ត្រនៃការវិវត្តខាងសាសនា ។

**គ) ចំពោះមនុស្សទូទៅ**

១. ជាប្រភពនៃគំនិតឲ្យកើតមានការរិះគិត និងការយល់ដឹងយ៉ាងទូលំទូលាយ

២. ណែនាំការរស់នៅឲ្យមានយុត្តិធម៌ និងសេចក្តីស្រឡាញ់

៣. ជាចម្លើយចំពោះសំណួរដែលមនុស្សគ្រប់គ្នាឆ្ងល់អំពីជីវិត ។

## III. ហេតុអ្វីបានជាគេសរសេរព្រះគម្ពីរ?

ក. ដើម្បីបង្រៀន រកខុសត្រូវ កែតម្រង់ និងអប់រំឲ្យរស់នៅតាមសេចក្តីពិត (២ធម ៣, ១៥-១៧)

២. ឲ្យចេះស៊ូទ្រាំនិងមានសេចក្តីសង្ឃឹម (រ ១៥, ៤)

៣. សម្រាប់លួងលោម និងការលើកទឹកចិត្ត (១មបា ១២, ៩)

៤. ដើម្បីបង្កើនជំនឿ និងឲ្យមានជីវិតអស់កល្បជានិច្ច (យហ ២០,៣១)

៥. ឲ្យទៅជាគ្រីស្តបរិស័ទដ៏ពិតប្រាកដ (លក១, ១-៤)



### ៧.អ្នកនឹងបានអានព្រះគម្ពីរទាំងមូលនៅទីបំផុត

ប្រសិនបើអ្នកបានចូលរួមថ្វាយអភិបូជាច្រើនដង នោះអ្នកដូចជាបានអានគម្ពីរ ជាច្រើនក័ណ្ឌដែរ ។ ដ្បិតអភិបូជាថ្ងៃអាទិត្យ មានអានគម្ពីរវិលជុំ បីឆ្នាំម្តង គឺឆ្នាំ ក, ខ, និងគ និងអភិបូជាថ្ងៃរាយ មានអានគម្ពីរវិលជុំ ពីរឆ្នាំម្តង គឺឆ្នាំសេស និងឆ្នាំគូ ។ យើងសូមលើកទឹកចិត្តអ្នកឲ្យចូលរួមថ្វាយអភិបូជាប្រចាំថ្ងៃ ។




### ៨. ជាឱកាសបានស្គាល់សន្តៈ សន្តីបុគ្គលជាច្រើន

អភិបូជា ជាឱកាសឲ្យអ្នកបានស្គាល់សន្តៈ ឬសន្តីបុគ្គលជាច្រើនថែមទៀត ក្រៅពីសន្តៈ ឬសន្តីបុគ្គលរបស់ខ្លួន ។ យើងសូមលើកទឹកចិត្តអ្នកឲ្យចូលរួមថ្វាយអភិបូជាប្រចាំថ្ងៃ ។



### ៣. អ្នកទទួលកម្លាំងទប់ទល់នឹងបាប

ព្រះកាយព្រះគ្រីស្តដែលអ្នកបានទទួលក្នុងពិធីអរព្រះគុណព្រះជាម្ចាស់ នៃអភិបូជាប្រចាំថ្ងៃ នឹងពង្រឹងជីវិតខាងវិញ្ញាណរបស់អ្នកធ្វើឲ្យអ្នកមានកម្លាំងល្មម ងាយទប់ទល់នឹងការល្បួងឲ្យប្រព្រឹត្តបាប ។



### ៤. អ្នកមានពេលថែមទៀតដើម្បីអធិដ្ឋាន

ការចូលរួមថ្វាយអភិបូជាប្រចាំថ្ងៃ នាំឲ្យអ្នកមានរបៀបរៀបរយក្នុងការរស់នៅ និងមានឱកាសដើម្បីនឹងអធិដ្ឋាន ។

### ៥. អ្នកមិនប្រើពេលយូរទេ



អភិបូជាប្រចាំថ្ងៃខ្លីជាងអភិបូជាថ្ងៃអាទិត្យ ដែលមិនសូវប៉ះពាល់លើការងាររវល់របស់អ្នកប៉ុន្មានទេ ។ មុនពេលអានគម្ពីរដំណឹងល្អមានអានអត្ថបទមួយ និងជាទូទៅមិនមានភ្លេងទេ ។ យើងប្រើពេលប្រមាណ ៣០ នាទីប៉ុណ្ណោះ ។ ដូច្នេះ អ្នកអាចចូលរួមបាន ។

### ៦. ពេលវេលាមិនស្មុគ្រស្មាញ

ព្រះសហគមន៍ជាច្រើនថ្វាយអភិបូជាប្រចាំថ្ងៃ នៅម៉ោង ៦:០០ព្រឹក ឬម៉ោង ៦:០០ ល្ងាច ជាពេលមុននិងក្រោយម៉ោងធ្វើការរបស់អ្នក ។ ដូច្នេះ អ្នកអាចចូលរួមបាន ។ យើងសូមលើកទឹកចិត្តអ្នកដើម្បីចូលរួម ។





៦. ឲ្យរស់នៅក្នុងសេចក្តីស្រឡាញ់ មិនមែនក្នុងបាប (យហ ២,១, ៧-១១)

៧. ដើម្បីបង្ហាញថា ព្រះគ្រីស្តយេស៊ូ ជាព្រះជាម្ចាស់ និងជាព្រះសង្គ្រោះ ។

## IV. គ័ណ្ឌនៃព្រះគម្ពីរ

ព្រះគម្ពីររួមផ្សំដោយគ័ណ្ឌទាំងអស់ចំនួន ៧៣ ហើយគេចែកជាពីរផ្នែកធំ គឺព្រះគម្ពីរសម្ពន្ធមេត្រីចាស់ និងព្រះគម្ពីរសម្ពន្ធមេត្រីថ្មី ។ ក្នុងគ័ណ្ឌនីមួយមានចែកជាជំពូក និង ខ ។

## V. ព្រះគម្ពីរសម្ពន្ធមេត្រីចាស់

ព្រះគម្ពីរសម្ពន្ធមេត្រីចាស់ សរសេរឡើងនៅពេលដែលចំណងនៃសម្ពន្ធមេត្រីចាស់ចូលជាធរមាន ។ ព្រះគម្ពីរសម្ពន្ធមេត្រីចាស់មានទាំងអស់ ៤៦គ័ណ្ឌ គឺជាគ័ណ្ឌគម្ពីរ ពីបុរាណរបស់ជនជាតិអ៊ីស្រាអែល ដែលរៀបរាប់ពីព្រះជាម្ចាស់ចងសម្ពន្ធមេត្រីជាមួយប្រជារាស្ត្ររបស់ព្រះអង្គ និងពីពួកគេរស់នៅតាមសម្ពន្ធមេត្រីនោះ តាំងពីសម័យលោកម៉ូសេ រហូតដល់សម័យព្រះយេស៊ូ ។ គេបានរៀបចំគ័ណ្ឌនៃគម្ពីរសម្ពន្ធមេត្រីចាស់តាមលំដាប់ដូចតទៅ៖

### គម្ពីរវិន័យ ឬ បញ្ចគ័ណ្ឌ

១. កំណើតពិភពលោក ២.សេរីភាព ៣. លេវីវិន័យ

៤. ជំរឿនប្រជាជន ៥. ទុតិយកថា

គម្ពីរវិន័យ ណែនាំឲ្យជនជាតិអ៊ីស្រាអែលយល់ដឹងអំពីកំណើត នៃពិភពលោក និងកំណើតរបស់ពូជសាសន៍ខ្លួន ។ ក្នុងនោះក៏មានចែងអំពីវិន័យច្បាប់ក្នុងការរស់នៅ និងអំពីរបៀបគោរពថ្វាយបង្គំព្រះជាម្ចាស់ដែរ ។

## គម្ពីរព្យាការី

- **ព្យាការីដើមដំបូង**

១. យូស៊ូអា ២. វិរបុរស ៣. សាមូអែល ទី១
៤. សាមូអែល ទី២ ៥. ពង្សាវតាក្សត្រ ទី១ ៦. ពង្សាវតាក្សត្រ ទី២

- **ព្យាការីជំនាន់ក្រោយ**

១. ព្យាការីអេសាយ ២. ព្យាការីយេរេមី
៣. ព្យាការីអេសេគីអែល ៤. ព្យាការីហូសេ
៥. ព្យាការីយ៉ូអែល ៦. ព្យាការីអម៉ូស
៧. ព្យាការីអូបាឌី ៨. ព្យាការីយ៉ូណាស
៩. ព្យាការីមីកា ១០. ព្យាការីណាហ៊ូម
១១. បាហាគូក ១២. សេផានី
១៣. ហាកាយ ១៤. ព្យាការីសាការី
១៥. ព្យាការីម៉ាឡាគី

គម្ពីរព្យាការីមានចែងពីពាក្យថ្លែងព្រះបន្ទូល និងការប្រព្រឹត្តរបស់ពួកព្យាការី ដែលព្រះជាម្ចាស់បានចាត់អស់លោកឲ្យមកប្រកាសព្រះបន្ទូលរបស់ព្រះអង្គ ក្នុងកាលៈទេសៈណាមួយ នៅក្នុងប្រវត្តិសាស្ត្រអ៊ីស្រាអែល ។ កណ្ឌយ៉ូណាសប្លែកពីគេ ដោយសាររៀបរាប់ពីព្យាការីម្នាក់ ដែលមានទម្រង់មិនមែនជាប្រវត្តិសាស្ត្រពិតទេ ។

## គម្ពីរកណ្ឌផ្សេងៗ

១. ទំនុកតម្កើង ២. យ៉ូប ៣. សុភាសិត
៤. នាងរូថ ៥. បទចម្រៀងសាឡូម៉ូន ៦. សាស្តា
៧. សំណោក ៨. អេសធែរ ៩. ដានីអែល
១០. អែសរ៉ា ១១.នេហេមី ១២. របាក្សត្រ ទី១
១៣. របាក្សត្រ ទី២



## មេរៀនទី ៤ ហេតុផល ៨ យ៉ាងដែលគ្រីស្តបរិស័ទចូលរួមថ្វាយអភិបូជាប្រចាំថ្ងៃ

ពិតណាស់ គ្រីស្តបរិស័ទត្រូវតែទៅថ្វាយអភិបូជារាល់ថ្ងៃអាទិត្យ ប៉ុន្តែរាល់ថ្ងៃក្រៅពីថ្ងៃអាទិត្យ ក៏ព្រះសហគមន៍ប្រារព្ធអភិបូជាដែរ លើកលែងតែថ្ងៃសុក្រពិសិដ្ឋ ។ ហេតុអ្វីបានជាមានអភិបូជាមិនឈប់ឈរដូច្នេះ? តាមពិតអភិបូជាអាចផ្លាស់ប្តូរជីវិតរបស់អ្នកយ៉ាងអស្ចារ្យនេះហើយជាហេតុផល ។

### ១. អ្នកបានទទួលព្រះយេស៊ូគ្រីស្ត



រាល់អភិបូជាប្រចាំថ្ងៃ អ្នកនឹងបានទទួលព្រះយេស៊ូគ្រីស្ត ក្នុងពិធីអរព្រះគុណព្រះជាម្ចាស់ ។ គ្មានបានអ្វីណាប្រសើរជាងបានទទួលព្រះយេស៊ូគ្រីស្តទេ ។

### ២. អ្នកបានទទួលការលើកលែងទោសរួចពីបាប



នៅដើមនៃអភិបូជា រួមទាំងអភិបូជាប្រចាំថ្ងៃផងអ្នកតែងសូត្រធម៌សារភាពបាបទាំងប្រែចិត្តពីបាបរបស់អ្នក ។ បន្ទាប់មកពិធីអរព្រះគុណព្រះជាម្ចាស់ក្នុងអភិបូជាក៏បានលុបបោលនូវបាបទាំងអស់នោះ ។ ការលុបបោលបាបនេះក៏កើតមានក្នុងអភិបូជា នៅថ្ងៃអាទិត្យដែរ ដូច្នេះមានន័យថា ជារៀងរាល់ថ្ងៃ គឺបាបរបស់អ្នកត្រូវបានសម្អាត ប៉ុន្តែនេះមិនមានន័យថា អ្នកមិនចាំបាច់សារភាពបាបម្តងទៀតនោះទេ ។

*តែជួបឧបសគ្គមករារាំងដែរ ។ ពេលលោកម៉ាកុសតែងគម្ពីរនេះ ជាពេលដែលគេកំពុងធ្វើទុក្ខបុកម្នេញព្រះសហគមន៍ក្រុងរ៉ូម ។ ព្រះយេស៊ូហាក់ដូចជាផ្ទំលក់ មិនអើពើនឹងគ្រីស្តបរិស័ទដែលកំពុងរងទុក្ខវេទនា ។ គ្រីស្តបរិស័ទក៏ស្រែកឡើងថា៖ «លោកគ្រូ! យើងស្លាប់ឥឡូវហើយ! លោកមិនអើពើទេឬ?» ។*

*ក្នុងអត្ថបទនេះ យើងម្នាក់ៗប្រៀបបីដូចសាវ័កពីដើម ដែលតែងតែជួបនូវឧបសគ្គជាច្រើន ។ ជួនកាលធ្វើឲ្យយើងភ័យព្រួយអស់សង្ឃឹម ។ ប៉ុន្តែកុំអស់សង្ឃឹម ព្រោះយើងកំពុងស្ថិតនៅក្នុងព្រះសហគមន៍របស់ព្រះយេស៊ូ ដូចសាវ័កពីដើមស្ថិតនៅក្នុងទូកជាមួយព្រះអង្គដែរ ។*



ជាក័ណ្ឌដែលថែងអំពីសីលធម៌ និងសេចក្តីប្រៀនប្រដៅសាសនា ឬសុភាសិត សម្រាប់អប់រំអំពីការរស់នៅ រួមទាំងសំណួរដ៏សំខាន់ផ្សេងៗទៀតរបស់មនុស្សយើង (ឧ. អំពីទុក្ខលំបាករបស់មនុស្សសុចរិត "យ៉ូប", អំពីសេចក្តីស្លាប់ "សាស្តា" និងអំពីការលើកតម្កើងសេចក្តីស្រឡាញ់របស់មនុស្ស "បទចម្រៀងស្តេចសាឡូម៉ូន"

**គម្ពីរទុតិយក័ណ្ឌ**

១. យូឌីត ២. តូប៊ីត ៣. ម៉ាកាបាយ ទី១
៤. ម៉ាកាបាយ ទី២ ៥. ព្រះប្រាជ្ញាញាណ ៦. បេនស៊ីរ៉ាក
៧. បារូក

ក័ណ្ឌទាំងប្រាំពីរនេះ ក្រុមជំនុំប្រូតេស្តង់មិនទទួលទុកជាព្រះគម្ពីរទេ ទុកគ្រាន់តែជាសៀវភៅសិក្សា ។ ហេតុដូច្នេះហើយ គម្ពីររបស់ប្រូតេស្តង់មានតែ ៦៦ ក័ណ្ឌប៉ុណ្ណោះ ។

## VI. ព្រះគម្ពីរសម្ពន្ធមេត្រីថ្មី

ព្រះគម្ពីរសម្ពន្ធមេត្រីថ្មី មានទាំងអស់ ២៧ ក័ណ្ឌ បានកត់ត្រាទុកនូវទុក្ខលំបាករបស់ព្រះយេស៊ូ ព្រះអង្គសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង និងអំពីព្រះបន្ទូលរបស់ព្រះអង្គផ្ដែផ្ដាំដល់មនុស្សលោក ។ មានកត់ត្រាទុកនូវបេសកកម្ម និងសកម្មភាពរបស់ក្រុមគ្រីស្តទូត និងលិខិតរបស់ពួកគេផ្ញើទៅលើកទឹកចិត្តដល់អស់អ្នកប្រែចិត្តទៅជាគ្រីស្តបរិស័ទថ្មី ។ គេរៀបចំក័ណ្ឌគម្ពីរសម្ពន្ធមេត្រីថ្មីតាមលំដាប់ដូចតទៅ៖

**គម្ពីរដំណឹងល្អ**

១. ក័ណ្ឌម៉ាថាយ ២. ក័ណ្ឌម៉ាកូស ៣. ក័ណ្ឌលូកា ៤. ក័ណ្ឌយ៉ូហាន

គម្ពីរដំណឹងល្អមាន៤ក័ណ្ឌ ថែងអំពីការរស់នៅរបស់ព្រះយេស៊ូ និងកិច្ចការរបស់ព្រះអង្គ ។

### គម្ពីរកិច្ចការគ្រីស្តទូត

មានតែមួយកណ្ឌ និងមានរៀបរាប់អំពីកំណើតដំបូងនៃព្រះសហគមន៍ និងការរីកចម្រើននៃលទ្ធិគ្រីស្តសាសនាក្រោមការណែនាំរបស់ព្រះវិញ្ញាណ ។

### គម្ពីរលិខិតគ្រីស្តទូត

| | | |
|---|---|---|
| ១. រ៉ូម | ២. ១ កូរិនថូស | ៣. ២កូរិនថូស |
| ៤. កាឡាទី | ៥. អេភេសូ | ៦. ភីលីព |
| ៧. កូឡូស | ៨. ១ ថេស្សាឡូនិក | ៩. ២ ថេស្សាឡូនិក |
| ១០. ១ ធីម៉ូថេ | ១១. ២ ធីម៉ូថេ | ១២. ទីតុស |

១៣.ភីឡេម៉ូន (ជាលិខិតសរសេរដោយគ្រីស្តទូតប៉ូល)

១៤. អេប្រឺ (សុន្ទរកថារបស់បណ្ឌិតខាងវិន័យម្នាក់)

| | | |
|---|---|---|
| ១៥. យ៉ាកុប | ១៦. ១សិលា | ១៧. ២ សិលា |
| ១៨. ១យ៉ូហាន | ១៩. ២ យ៉ូហាន | ២០. ៣ យ៉ូហាន |

២១. យូដាស (ជាលិខិតកាតូលិក មានន័យថា សកល តាមអត្ថន័យនេះលិខិតទាំងនេះគឺផ្ញើជូនគ្រីស្តបរិស័ទទាំងអស់) ។

កណ្ឌទាំងអស់មានចែងពីជំនឿ របស់គ្រីស្តបរិស័ទនិងសេចក្តីប្រៀនប្រដៅផ្សេងៗឲ្យគ្រីស្តបរិស័ទប្រព្រឹត្តតាម ។ សេចក្តីណែនាំជាច្រើន គឺជាការឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ព្រះសហគមន៍ នៅសម័យដើមដំបូងនោះ ។

### គម្ពីរវិវរណៈ

មានតែមួយកណ្ឌ ចែងអំពីចក្ខុនិមិត្ត និងសញ្ញាគួរឲ្យចាប់អារម្មណ៍ ដើម្បីលើកទឹកចិត្តខាងជំនឿដល់សហគមន៍គ្រីស្តបរិស័ទដែលកំពុងប្រឈមនឹងការបៀតបៀន និងក៏មានចែងយ៉ាងជាក់លាក់អំពីព្រឹត្តិការណ៍នាពេលអនាគត នៅចុងបញ្ចប់នៃពេលវេលា ។



## វិធីទី-២

### ព្រះយេស៊ូធ្វើឲ្យរលកស្ងប់

ព្រះយេស៊ូបង្រៀនបណ្តាជននៅតាមឆ្នេរសមុទ្រអស់មួយថ្ងៃ នៅល្ងាចថ្ងៃដដែលនោះ ព្រះអង្គមានបន្ទូលទៅកាន់ពួកសាវ័កថា៖ «យើងនាំគ្នាឆ្លងទៅត្រើយម្ខាង» ។ ពួកសាវ័កក៏ចេញទូកពីបណ្តាជន ហើយអុំទូកដែលមានព្រះយេស៊ូគង់នៅក្នុងនោះ ដោយមានទូកឯទៀតៗទៅជាមួយដែរ ។ ស្រាប់តែមានខ្យល់ព្យុះបោកបក់មកយ៉ាងខ្លាំង ហើយរលកក៏បក់បោកប៉ះនឹងទូកបណ្តាលឲ្យទឹកចូលស្ទើរពេញ ។ រីឯព្រះយេស៊ូវិញ ព្រះអង្គផ្ទំលក់លើខ្នើយនៅកន្សៃទូក ។ ពួកសាវ័កដាស់ព្រះអង្គថា៖ «លោកគ្រូយើងស្លាប់ឥឡូវហើយ! លោកមិនអើពើទេឬ?» ។ ព្រះយេស៊ូតើនឡើង មានព្រះបន្ទូលគំរាមខ្យល់ព្យុះនិងបញ្ជាសមុទ្រថា៖ «ស្ងប់ស្ងៀមទៅ!» ។ ពេលនោះខ្យល់ព្យុះក៏ស្ងប់ ហើយផ្ទៃទឹកក៏រាបស្មើដែរ ។ បន្ទាប់មកព្រះយេស៊ូមានព្រះបន្ទូលទៅពួកសាវ័កថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាភិតភ័យដូច្នេះ? អ្នករាល់គ្នាមិនទាន់មានជំនឿទេឬ?» ។ ពួកសាវ័កកោតស្ញប់ស្ញែងជាខ្លាំង ហើយនិយាយគ្នាទៅវិញទៅមកថា៖ «តើ លោកនេះជានរណាបានជាខ្យល់ព្យុះ និងសមុទ្រស្តាប់បង្គាប់លោកដូច្នេះ?» ។

(មក ៤,៣៥-៤១)

*នៅល្ងាច ជាពេលដែលយើងសង្ស័យ ជាពេលធ្វើបាប ជាពេលដែលមារ គ្រងរាជ្យ ។*

*ត្រើយម្ខាង ប្រជាជននៅទីនោះ មិនមែនជនជាតិទេ គេមិនជឿ លើព្រះជាម្ចាស់ទេ គឺជាអ្នកស្រុក ដែលមាត្រួតត្រា ។*

*ព្រះយេស៊ូផ្ទំ គឺតាំងពីពេលព្រះយេស៊ូ សោយទិវង្គត ព្រះអង្គដូចជាមិនអើពើ ។*

*សមុទ្រ ក្នុងគម្ពីរសមុទ្រជាទីលំនៅរបស់មារ និងខ្មោចទាំងអស់ ។*

*ស្ងប់ស្ងៀមទៅ! ព្រះយេស៊ូឃុំឃាំងខ្មោច នៅកន្លែងរបស់វា (ដូច មក១,២៥) ។*

### សេចក្តីពន្យល់

*នៅពេលព្រះយេស៊ូ និងសាវ័កកំពុងធ្វើដំណើរទៅកាន់ទឹកដីដែលសាសន៍ដទៃរស់នៅ ព្យុះកើតឡើងមានន័យថា៖ ពេលព្រះសហគមន៍ប្រកាសដំណឹងល្អ ត្រូវ*

- **អំពីខ្លួនខ្ញុំ៖** មនុស្សម្នាក់ៗសុទ្ធតែជាប់សេចក្តីអាក្រក់នៅក្នុងខ្លួន ។ ខ្ញុំក៏មានសេចក្តីអាក្រក់នៅក្នុងចិត្ត ខ្ញុំត្រូវពឹងផ្អែកលើព្រះយេស៊ូ ដើម្បីឲ្យព្រះអង្គដាក់ព្រះហស្តលើខ្ញុំ ឲ្យខ្ញុំជាសះស្បើយពីសេចក្តីអាក្រក់ទាំងឡាយ ។

៧. អធិដ្ឋាន អរព្រះគុណតាមរយៈអត្ថបទនេះ

- អរព្រះគុណព្រះយេស៊ូ ដែលបានព្យាបាលមនុស្សគរថ្លង់
- អង្វរព្រះយេស៊ូ នាំយើងឲ្យមានទំនាក់ទំនងល្អជាមួយព្រះអង្គ
- សូមព្រះយេស៊ូព្យាបាលយើងទាំងអស់គ្នាដែល គ ថ្លង់ ពីកំណើត
- អរព្រះគុណព្រះយេស៊ូដែលស្តាប់ឮពាក្យត្អូញថ្ងូររបស់យើង
- អរព្រះគុណព្រះយេស៊ូកំពុងបង្កើតប្រជារាស្ត្រថ្មី ដែលស្តាប់នឹងមើលឃើញនូវស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ។ ខ្ញុំជាអ្នកជឿត្រូវតែប្រកាសដំណឹងល្អ ស្តីអំពីការសង្គ្រោះឲ្យមនុស្សគ្រប់ជាតិសាសន៍ក្នុងលោកដឹងឮ ។
- យើងជាមនុស្សគ និងថ្លង់មិនចេះនិយាយអំពីព្រះជាម្ចាស់ ។ ព្រះយេស៊ូប្រោសប្រណីឲ្យយើងជឿលើព្រះអង្គ ឲ្យយល់អត្ថន័យព្រះបន្ទូលឲ្យស្តាប់ព្រះអង្គមានព្រះបន្ទូលមកយើងតាមរយៈអ្នកដទៃ ។ល ។ ព្រះអង្គប្រោសយើងឲ្យអាចប្រកាសដំណឹងល្អបានឲ្យលើកតម្កើងព្រះជាម្ចាស់ ។
- ព្រះយេស៊ូដាក់អង្គុលីក្នុងត្រចៀក និងពាល់អណ្តាតអ្នកគ ថ្លង់ ឲ្យគាត់ស្តាប់ឮ និងនិយាយបាន ។ កាយវិការនេះ ជានិមិត្តរូបអំពីអគ្គសញ្ញាជ្រមុជទឹក គឺជីវិតថ្មី និងអគ្គសញ្ញាលាបថ្ងាស គឺព្រះអង្គប្រទានឲ្យយើងមានចិត្តក្លាហាន ដើម្បីប្រកាសជំនឿ ។



# មេរៀនទី ២ ហេតុអ្វីយើងអានព្រះគម្ពីរ

## ១. ដើម្បីដឹងថាព្រះជាម្ចាស់ចង់ឲ្យយើងធ្វើអ្វី

"គ្រប់អត្ថបទគម្ពីរ សុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺឲ្យតែង និងមានប្រយោជន៍សម្រាប់បង្រៀនរកខុសត្រូវកែតម្រង់ និងអប់រំឲ្យរស់នៅតាមសុចរិត" (២ ធម ៣:១៦)

*ពាក្យដាស់តឿន ណែនាំ លើកទឹកចិត្តក្នុងគម្ពីរ នាំឲ្យយើងយល់ច្បាស់អំពីបំណងរបស់ព្រះជាម្ចាស់ចំពោះយើង ក្នុងគ្រប់ទិដ្ឋភាពនៃជីវិត ។*

## ២. ជាអាហារបំប៉នរបស់យើង

"ក្នុងគម្ពីរមានចែងថា៖ មនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ គឺរស់ដោយសារគ្រប់ព្រះបន្ទូលដែលចេញមកពីព្រះឱស្ឋរបស់ព្រះជាម្ចាស់ដែរ" (មថ ៤,៤) ។

"មានតែព្រះវិញ្ញាណទេដែលផ្តល់ជីវិត និស្ស័យលោកីយ៍មិនអាចផ្តល់ជីវិតបានឡើយ ។ រីឯពាក្យទាំងប៉ុន្មានដែលខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នា សុទ្ធតែចេញមកពីព្រះវិញ្ញាណ ដែលផ្តល់ជីវិត" (យហ ៦,៦៣) ។

*ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាប្រភពនៃជីវិត! ផ្តល់កម្លាំងនិងប្រាជ្ញាគ្មានព្រំដែន ។ ពេលយើងអានឬស្តាប់តាមស្មារតីនៃសេចក្តីជំនឿ នាំយើងឱ្យមានការរីកចម្រើនខាងព្រលឹងវិញ្ញាណដែលមិនអាចនឹកស្មានដល់ ។*

## ៣. នាំឲ្យយើងចេះវែកញែក

"ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាព្រះបន្ទូលដ៏មានជីវិត និងមានមហិទ្ធិឫទ្ធិ

មុតជាងដាវមុខពីរទៅទៀត ។ ព្រះបន្ទូលនេះចាក់ទម្លុះចូលទៅកាត់ព្រលឹង និងវិញ្ញាណដាច់ចេញពីគ្នា កាត់សន្លាក់ឆ្អឹង និងខួរឆ្អឹងចេញពីគ្នា ។ ព្រះបន្ទូលវិនិច្ឆ័យឆន្ទៈនិងគំនិតនៅក្នុងជម្រៅចិត្តមនុស្ស" (ហប ៤, ១២) ។

"អ្នកឯទៀតៗគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនទាំងអស់គ្នា គេមិនគិតពីប្រយោជន៍របស់ព្រះយេស៊ូគ្រីស្តទេ" (ភល ២,២១) ។

"ពាក្យរបស់យើងប្រៀបបីដូចជាភ្លើង និងដូចជាញញួរដំបំបែកថ្ម" (យរ ២៣,២៩) ។

## ៤. ព្រះគម្ពីរណែនាំយើងដោយសេចក្តីសុចរិត

"តើមនុស្សកំលោះត្រូវធ្វើយ៉ាងណា ដើម្បីឲ្យកិរិយាមារយាទរបស់ខ្លួនបានល្អត្រឹមត្រូវ? គឺដោយប្រណិប័តន៍ព្រះបន្ទូលរបស់ព្រះអង្គ"(ទន ១១៩,៩) ។

"គ្រប់អត្ថបទគម្ពីរ សុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺឲ្យតែង និងមានប្រយោជន៍សម្រាប់បង្រៀន រកខុសត្រូវ កែតម្រង់ និងអប់រំឲ្យរស់នៅតាមសេចក្តីសុចរិត ១៧ ក្នុងគោលបំណងឲ្យអ្នកបម្រើរបស់ព្រះជាម្ចាស់មានសមត្ថភាព និងប្រុងប្រៀបខ្លួនជាស្រេចដើម្បីប្រព្រឹត្តអំពើល្អគ្រប់ជំពូក" (២ ធម ៣, ១៦-១៧) ។

## ៥. ដើម្បីឲ្យយើងមានថាមពលអាចយកឈ្នះបាន

"ម្នាក់ៗជួបនឹងការល្បួង មកតែពីចិត្តលោភលន់របស់ខ្លួនឯងផ្ទាល់ ទាក់ទាញ និងលួងលោមបញ្ឆោតប៉ុណ្ណោះ" (យក ១,១៤) ។

ចំពោះព្រះយេស៊ូ ព្រះអង្គតែងមានប្រតិកម្មតបនឹងការល្បួងនីមួយៗដែលព្រះអង្គបានប្រឈម ដោយពឹងផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ជានិច្ច ។ ព្រះ



- *ជួនកាលខ្ញុំជាមនុស្សថ្លង់ ស្តាប់មិនឮព្រះជាម្ចាស់ត្រាស់ហៅខ្ញុំ ឬបងប្អូនប្រុសស្រីរបស់ខ្ញុំហៅខ្ញុំទេ ។*
- *ជួនកាលខ្ញុំជាមនុស្សគ មិនព្រមនិយាយអំពីជំនឿប្រាប់បងប្អូនឯទៀត ។ ដូច្នេះ ខ្ញុំពិតជាត្រូវការបងប្អូនឯទៀតជួយនាំខ្ញុំទៅរកព្រះយេស៊ូ ។*
- *ជួនកាលខ្ញុំដូចអ្នកដែលនាំមនុស្សថ្លង់មកជួបព្រះយេស៊ូដែរ គឺខ្ញុំទូលអង្វរព្រះអង្គសម្រាប់បងប្អូនឯទៀតៗ ។*
- *ជួនកាលខ្ញុំច្រៀងកោតសរសើរព្រះយេស៊ូ ប្រកបដោយចិត្តអរសប្បាយទៀតផង ។*
- *ជួនកាលខ្ញុំដូចព្រះយេស៊ូ ដោយខ្ញុំទុកឱកាសឲ្យបងប្អូនឯទៀតៗមកនិយាយហើយខ្ញុំស្តាប់យោបល់របស់គេ ។*

៦. ក្នុងអត្ថបទនេះតើអ្នកនិពន្ធមានបំណងបង្រៀនអ្វីខ្លះ? អំពីព្រះជាម្ចាស់? អំពីព្រះយេស៊ូ? អំពីខ្លួនខ្ញុំ?

- ***អំពីព្រះជាម្ចាស់៖*** *ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសណ្តោស ចាត់ព្រះបុត្រាឲ្យយាងមកបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គ ដោយប្រោសមនុស្សឲ្យមានសេរីភាព ចេញពីភាពងងឹត គ ថ្លង់... ។*
- ***អំពីព្រះយេស៊ូ៖*** *ព្រះយេស៊ូធ្វើកិច្ចការទាំងនេះមិនមែនដើម្បីលុយកាក់ ឬល្បីឈ្មោះទេ គឺព្រះអង្គចង់ឲ្យអ្នកកាន់សាសនាស្តាប់ព្រះបន្ទូល និងច្រៀងលើកតម្កើងព្រះជាម្ចាស់ ។ ក្នុងអត្ថបទនេះ គឺសុទ្ធតែជាសាសន៍ដទៃច្រៀងកោតសរសើរព្រះយេស៊ូដែលធ្វើការងារ "ល្អ" ដូចនៅក្នុងអត្ថបទគម្ពីរកំណើតដែលព្រះជាម្ចាស់បង្កើតផែនដី និងផ្ទៃមេឃ «ព្រះអង្គទតឃើញ និងយល់ថា អ្វីៗទាំងអស់ដែលព្រះអង្គបានបង្កើតមក ល្អប្រសើរបំផុតហើយ» ។ ពេលនេះ ព្រះជាម្ចាស់ផ្តើមបង្កើតប្រជាជនថ្មីមួយនៅក្នុងលោកនេះ ។*

៣. កត់ឈ្មោះតួនីមួយៗ គេទៅណា? មកពីណា? គេធ្វើអ្វី? និយាយអ្វី?

- *កាយវិការគេក្រោកឬដេក និងពាក្យសម្ដីនីមួយៗសុទ្ធតែមានអត្ថន័យ ។ ឧ. ព្រះយេស៊ូឆ្លងកាត់ដំបន់ដេកាប៉ូល៖ ព្រះយេស៊ូនៅខាងក្រៅស្រុកអ៊ីស្រាអែល គឺព្រះអង្គប្រោសសាសន៍ដទៃជានិមិត្តរូបដែលសាសន៍ដទៃបានទទួលដំណឹងល្អពីគ្រីស្តទូត ។ ព្រះអង្គនាំគាត់ចេញទៅដាច់ពីបណ្ដាជន៖ ព្រះអង្គប្រោសអ្នកពិការមិនមែនដោយព្រះបំណងធ្វើឲ្យមហាជន ស្ងើចសរសើរព្រះអង្គទេ គឺព្រះអង្គសម្ដែងបាដិហារិយ៍ដើម្បីពង្រឹងជំនឿអ្នកស្រុកវិញ ។*

៤. ចាប់ពីដើមដល់ចុងអត្ថបទ តើសភាពការណ៍មានការផ្លាស់ប្ដូរបែបណា? អ្វីដែលធ្វើឲ្យសភាពការណ៍ផ្លាស់ប្ដូរដូច្នេះ?

- *ឧ. កាលដំបូង ព្រះយេស៊ូគង់នៅតែមួយអង្គឯង ក្នុងស្រុកសាសន៍ដទៃ ។ ទីបញ្ចប់មានសាក្សីជាច្រើនច្រៀងកោតសរសើរព្រះអង្គ ។ បរិយាកាសផ្លាស់ប្ដូរ គឺត្រចៀកមនុស្សថ្លង់បានឮ អណ្ដាតគេគ្រលាស់បានយ៉ាងត្រឹមត្រូវ ។ ដោយសារហេតុទាំងនោះ អ្នកកាន់សាសនាដទៃចោមរោមជុំវិញព្រះយេស៊ូ និងកោតសរសើរនូវអ្វីដែលព្រះអង្គបានធ្វើ ។*
- *ព្រះអង្គហាមពួកគេមិនឲ្យនិយាយប្រាប់នរណា៖ តាមគោលគំនិតរបស់លោកម៉ាកុស មនុស្សពុំអាចស្គាល់ថាន: ព្រះយេស៊ូជាព្រះគ្រីស្ត មុនពេលព្រះអង្គសោយទិវង្គតបានទេ ។ ព្រះអង្គហាមគេ ក្រែងគេច្រឡំថា ព្រះអង្គជាស្ដេច តាមរបៀបលោកីយ៍ ។*

៥. តើអត្ថបទនេះខ្លួនខ្ញុំប្រៀបដូចជានរណា?



យេស៊ូមានព្រះបន្ទូលទៅមារថា៖ “ក្នុងគម្ពីរមានចែងទៀតថា កុំល្បងលព្រះអម្ចាស់ជាព្រះរបស់អ្នកឡើយ ។ ដ្បិតមានសេចក្ដីចែងទុកមកថា អ្នកត្រូវថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះអង្គប៉ុណ្ណោះ” (មថ ៤,១-១១) ។

“ត្រូវបម្រើម្ចាស់ដោយស្ម័គ្រចិត្ត ដូចបម្រើព្រះអម្ចាស់ ពុំមែនបម្រើមនុស្សទេ” (អភ ៦, ១៧)

## ៦. ដើម្បីអ្នកទទួលព្រះបន្ទូល

“ចូរផ្ទៀងត្រចៀកស្ដាប់សេចក្ដី ដែលព្រះវិញ្ញាណមានព្រះបន្ទូល មកកាន់ព្រះសហគមន៍ទាំងនេះឲ្យមែនទែន! ។ អ្នកណាមានជ័យជម្នះ យើងនឹងឲ្យអ្នកនោះបរិភោគផ្លែឈើ ដែលបេះពីដើមនៃជីវិត នៅក្នុងសួនឧទ្យានរបស់ព្រះជាម្ចាស់” (វវ ២: ៧) ។

ព្រះបន្ទូលសន្យាដែលមិនចេះរីងស្ងួតជាច្រើន បានកើតឡើងចំពោះអស់អ្នកដែលបានរស់នៅស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។ តើអ្នកចាប់អារម្មណ៍នឹងការសន្យាដ៏មានតម្លៃទាំងនេះទេ? តើអ្នកចង់ឃើញអ្វីដែលព្រះជាម្ចាស់បានធ្វើរួចហើយ ហើយនឹងធ្វើសម្រាប់អស់អ្នកដែលរស់នៅស្របតាមព្រះហឫទ័យរបស់ព្រះអង្គឬទេ បើចាប់អារម្មណ៍ បន្ទាប់ទៅចូរអ្នកចាប់ផ្ដើមអានព្រះគម្ពីរ តាមគ្រប់មធ្យោបាយទៅ នោះព្រះគម្ពីរនឹងប្រាប់អ្នកអំពីការសន្យាទាំងអស់ដែលអាចជារបស់អ្នក ទាំងនៅក្នុងជីវិតនេះនិងជីវិតលោកខាងមុខ ជារៀងរហូតតទៅប្រសិនបើអ្នករស់នៅស្របតាមឆន្ទៈរបស់ព្រះអង្គ ។

## មេរៀនទី ៣ របៀបអានព្រះគម្ពីរ វិធីអានព្រះគម្ពីរ

ព្រះបន្ទូលជាអាហារចិញ្ចឹមជីវិតខាងវិញ្ញាណរបស់យើង ។ រាល់ពេលអានព្រះគម្ពីរ សូមបងប្អូនរិះគិតឲ្យល្អិតល្អន់ នោះទើបអត្ថបទព្រះគម្ពីរក្លាយទៅជាព្រះបន្ទូល ។ ព្រះគម្ពីគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ គ្រីស្តបរិស័ទតែងនិយាយថា "ព្រះវិញ្ញាណបំភ្លឺអ្នកនិពន្ធព្រះគម្ពីរ" ។ តាំងពីដើមរៀងមក គ្រីស្តបរិស័ទខិតខំពន្យល់អំពីរបៀបដែលព្រះជាម្ចាស់ណែនាំអ្នកនិពន្ធគម្ពីរ ។ គ្រីស្តបរិស័ទខ្លះយល់ឃើញថា ព្រះជាម្ចាស់បំភ្លឺអ្នកនិពន្ធ ហាក់ដូចជាព្រះអង្គពោលហើយអ្នកនិពន្ធសរសេរតាម ។ អ្នកដែលយល់ដូច្នេះមិនចាប់អារម្មណ៍អំពី "ព្រះបន្ទូលកើតមកជាមនុស្ស" (យហ ១,១៤) និងអំពីព្រះអង្គណែនាំអ្នកនិពន្ធទេ ។

" នៅជំនាន់ដើមព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់បុព្វបុរសយើងច្រើនលើកច្រើនសារ ដោយប្រើរបៀបផ្សេងៗជាច្រើនតាមរយៈពួកព្យាការី ។ គ្រានេះជាគ្រាចុងក្រោយបំផុត ព្រះអង្គមានព្រះបន្ទូលមកយើង តាមរយៈព្រះបុត្រា" (យហ ១,១-២) ។ នេះមានន័យថា ព្រះជាម្ចាស់បានបំភ្លឺអ្នកនិពន្ធតាមបច្ចេកទេស អរិយធម៌ ចំណេះដឹង កង្វល់ នឹងតាមសេចក្តីត្រូវការរបស់គេ ។ល ។

ចំពោះយើងជាអ្នកអានព្រះគម្ពីរសព្វថ្ងៃ ត្រូវតែបកស្រាយអត្ថន័យគម្ពីរ ដោយខិតខំស្វែងរកបទពិសោធន៍អ្នកនិពន្ធ ដែលជឿលើព្រះជាម្ចាស់ មកពន្យល់តាមសភាពការណ៍បច្ចុប្បន្នវិញ ហើយយើងជឿថា ព្រះវិញ្ញាណដ៏វិសុទ្ធតែមួយ ដែលមានព្រះបន្ទូលទៅគេ និងមកយើងសព្វថ្ងៃនេះដែរ ។

សព្វថ្ងៃប្រសិនបើយើងអានអត្ថបទព្រះគម្ពីរ យល់តាមអត្ថន័យត្រង់ៗ ដូចក្នុងព្រះគម្ពីរចែងនោះនាំឲ្យយើងស្មានថា រឿងនោះកើតឡើងពិតៗដូចមានចែងមែន ហើយជឿស៊ុបតាមសាច់រឿងនោះតែម្តង ។ យើងមុខជាមានចិត្តចង្អៀតចង្អល់ និងមើលងាយវប្បធម៌ផ្សេង ដែលផ្ទុយពីវប្បធម៌រស់ខ្លួនជាមិនខាន ព្រោះ



យើងយល់ថា រឿងរបស់គេនោះហួសសម័យឬគ្មានការពិតសោះ ។ ឧទាហរណ៍ ព្រះជាម្ចាស់បង្កើតពិភពលោកក្នុងរយៈពេល៦ថ្ងៃ... ។ ដូច្នេះពេលយើងអានព្រះគម្ពីរ ជាការចាំបាច់ណាស់យើងត្រូវមានរបៀបគិតដើម្បីយល់អត្ថន័យឲ្យច្បាស់ និងមានប្រយោជន៍សម្រាប់ការរស់នៅរបស់យើងសព្វថ្ងៃ ។

### វិធីអានគម្ពីរខ្លះៗដែលជួយយើងឲ្យយល់អត្ថន័យ៖

**វិធីទី -១**

១. ត្រូវអានអត្ថបទទាំងស្រុង ។
២. អានម្តងទៀតទាំងកត់សេចក្តីដែលខ្លួនឆ្ងល់ ។
៣. កត់ឈ្មោះតួនីមួយៗ គេទៅណា? មកពីណា? គេធ្វើអ្វី? និយាយអ្វី? ប្រហែលមានអត្ថន័យពិសេស ។ គេក្រោកឬដេក?
៤. ចាប់ពីដើមដល់ចប់សភាពការណ៍ផ្លាស់ប្តូរយ៉ាងណា? អ្វីដែលធ្វើឲ្យសភាពការណ៍ផ្លាស់ប្តូរដូច្នេះ?
៥. តើអត្ថបទនេះ ខ្លួនខ្ញុំប្រៀបដូចអ្នកណា? មានចិត្តដូចអ្នកណា?
៦. តើអត្ថបទនេះអ្នកនិពន្ធបង្រៀនអ្វីខ្លះអំពីព្រះជាម្ចាស់? អំពីព្រះយេស៊ូ? អំពីខ្លួនខ្ញុំ?
៧. អធិដ្ឋានអរព្រះគុណតាមរយៈអត្ថបទនោះ

### សេចក្តីពន្យល់

១. ត្រូវអានអត្ថបទទាំងស្រុង
   - *គោលបំណងឲ្យស្គាល់សាច់រឿង*

២. អានទាំងស្រុងម្តងទៀត ទាំងកត់សេចក្តីដែលខ្លួនឆ្ងល់ និងកត់សំណួរផ្សេងៗ
- *គោលបំណងឲ្យចាំសាច់រឿង*